ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៣៦...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំដាក់ឲ្យដំណើរការ មជ្ឈមណ្ឌលតំបន់អាស៊ាន សម្រាប់សកម្មភាពមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/២៦៥ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អោយទៅជាស្ថាប័នជាតិមួយ
- បានឃើញអនុក្រឹត្យលេខ១០០ អនក្រ/បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន
- តាមសំណើរបស់ក្រុមការងាររួមរវាង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ាន ស្តីពីការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ាន សម្រាប់សកម្មភាពមីន ដែលបានអនុម័ត នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ នៅទីក្រុងភ្នំពេញ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២។
- យោងតាមលក្ខខ័ណ្ឌប្រតិបត្តិ (TOR) ស្តីពីមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារអន្តរក្រសួង សម្រាប់រៀបចំដាក់ឲ្យដំណើរការមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន ដូចខាងក្រោម៖

១- ឯកឧត្តម **ព្រំ សុភមង្គល** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ជាប្រធាន។

២- ឯកឧត្តម **អ៊ុក សោភ័ណ** អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម **លី បញ្ញារិទ្ធី** អគ្គលេខាធិការរងអាជ្ញាធរកម្ពុជាគ្រប់គ្រង សកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន ជាអនុប្រធាន។

៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **សួស អន្ធារ៍** អគ្គស្នងការរងនគរបាលជាតិនៃក្រសួងមហាផ្ទៃ ជាសមាជិក។

៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **កែន សួសារឿន** អគ្គនាយករងមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម ក្រសួងការពារជាតិ ជាសមាជិក។

៥- ឯកឧត្តម **អ៊ុំ ភូមិរ៉ូ** អគ្គនាយករងនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ជាសមាជិក។

៦- ឯកឧត្តមឧត្តមសេនីយ៍ទោ **ឆាម ម៉ុនសេខ** ប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ ក្រសួងមហាផ្ទៃ ជាសមាជិក។



www.pheakdeylaw.com

៧- ឯកឧត្តមឧត្តមសេនីយ៍ត្រី **ជា សារិន** នាយករងនាយកដ្ឋានកិច្ចការអាស៊ាននៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ ជាសមាជិក។

៨- ឯកឧត្តម **ព្រហ្ម សួនប្រសិទ្ធ** ទីប្រឹក្សាអមក្រុមប្រឹក្សាមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ គ្រប់គ្រងគម្រោងជំនួយមនុស្សធម៌ មជ្ឈមណ្ឌលសកម្មភាព កំចាត់មីនកម្ពុជា ជាសមាជិក។

៩- លោក **ឈុំ ពិសិដ្ឋ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក។

១០- លោក **គង់ រដ្ឋា** ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាននៃអគ្គនាយកដ្ឋានសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក។

១១- លោក **អ៊ិន សុម៉េធ** អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច និងថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក។

១២- លោក **ហុក សុភា** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក។

១៣- កញ្ញា **នៀម កញ្ចនា** ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក។

**ប្រការ២._**

ក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំដាក់ឲ្យដំណើរការមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន មានភារកិច្ច៖

- សម្របសម្រួលការងាររួមជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាការដាក់ឲ្យដំណើរការមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១៦។
- រៀបចំនីតិវិធី និងគោលការណ៍សម្រាប់ការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីនសម្រាប់ថ្នាក់ជាតិកម្ពុជា។
- រៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។
- បន្តគាំទ្រតំណាងកម្ពុជា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។

**ប្រការ៣._**

ក្រុមការងារមានសិទ្ធិប្រើប្រាស់កញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់ការងារប្រចាំថ្ងៃរបស់ក្រុមការងារដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាអ្នករៀបចំគម្រោងសំណើថវិកានេះ។



www.pheakdeylaw.com

**ប្រការ៤._**

ក្រុមការងារត្រូវធ្វើរបាយការណ៍ និងលើកសំណើអនុសាសន៍សំខាន់ៗជូនឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាជ្ញាធរគ្រប់ក្រសួង ស្ថាប័នខេត្ត-ក្រុងពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលារាជធានី/ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com